ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ៤៣៥៥ ព.ណ. ......

ភ្នំពេញ, ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១១

# សេចក្តីជូនដំណឹង (បន្ថែមលើកទី២)
## ស្តីពីការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការឱ្យចូលបម្រើការងារ
## ក្នុងក្របខ័ណ្ឌក្រសួងពាណិជ្ជកម្ម ឆ្នាំ ២០១១

- យោងលិខិតលេខ ១០៥៥ សជណ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងលិខិតលេខ ១៧៩ មស.ក្រខ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០១១ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងសេចក្តីជូនដំណឹង លេខ ៣២៨៣ ពណ.បល ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០១១ របស់ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្មសូមជម្រាបជូនដំណឹងដល់សិស្ស និស្សិត និងសាធារណៈជនឱ្យបានជ្រាបថា ៖ ក្រសួងពាណិជ្ជកម្មនឹងធ្វើការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងក្នុងឆ្នាំ២០១១នេះ ចំនួន ២០កន្លែង ដើម្បីបម្រើការងារនៅទីស្តីការក្រសួង (ក្រៅពីចំនួន ២១នាក់ដែលជ្រើសរើសសម្រាប់មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត)។

ក្របខ័ណ្ឌដែលត្រូវជ្រើសរើស ជាប្រភេទក្របខ័ណ្ឌ « ក » សម្រាប់ផ្នែកជំនាញ ដូចខាងក្រោម ៖
- គីមីសាស្ត្រ ជីវគីមីសាស្ត្រ ឬមីក្រូជីវសាស្ត្រ ចំនួន ១០កន្លែង
- ព័ត៌មានវិទ្យា និងឯកទេសគ្រប់គ្រងដំណើរការគេហទំព័រ ចំនួន ០២កន្លែង
- ជំនាញទូទៅដែលទាក់ទងនឹងវិស័យគ្រប់គ្រងសេដ្ឋកិច្ច ពាណិជ្ជកម្ម ហិរញ្ញវត្ថុ សវនកម្ម គណនេយ្យ ទំនាក់ទំនងអន្តរជាតិ រដ្ឋបាលទូទៅ ច្បាប់ និងភាសាអង់គ្លេស ចំនួន ០៨កន្លែង

**ក-លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស :**

១- បេក្ខជនទាំងពីរភេទ ត្រូវមានសញ្ជាតិខ្មែរ

២- មានសញ្ញាប័ត្រចាប់ពីបរិញ្ញាបត្រឡើងទៅ ឬសញ្ញាប័ត្រមានតម្លៃសមមូល និងត្រូវមានអាយុមិនលើសពី ៣០ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។

៣- បេក្ខជនទាំងអស់ ត្រូវមានចំណេះដឹងជាមូលដ្ឋានលើជំនាញកុំព្យូទ័រ (Microsoft Word & Excel) ដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាត្រឹមត្រូវ។

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារៈ(៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*

**ខ-កាលបរិច្ឆេទទទួលពាក្យ និងទីកន្លែងទទួលពាក្យសុំប្រឡង :**

- ការទទួលពាក្យសុំចុះឈ្មោះប្រឡង នឹងប្រព្រឹត្តទៅនៅរៀងរាល់ម៉ោងធ្វើការ ចាប់ផ្តើមពីថ្ងៃជូនដំណឹងនេះ រហូតដល់ **ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១១** ត្រឹមវេលាម៉ោង១៧:០០ ជាកាលបរិច្ឆេទចុងក្រោយ។
- បេក្ខជន ត្រូវសរសេរ និងបំពេញសំណុំលិខិតសុំចុះឈ្មោះប្រឡង ហើយត្រូវមកដាក់ពាក្យសុំចុះឈ្មោះប្រឡងប្រជែងដោយខ្លួនឯង នៅលេខាធិការដ្ឋាននៃគណៈកម្មការប្រឡងប្រជែងរបស់ក្រសួងពាណិជ្ជកម្ម (នាយកដ្ឋានបុគ្គលិក ក្រសួងពាណិជ្ជកម្ម)។

**គ-សំណុំលិខិតសុំចុះឈ្មោះប្រឡង :**

| | |
|---|---|
| ១-ពាក្យសុំចុះឈ្មោះប្រឡងមានបិទតែមប្រិ៍យ | ចំនួន ០១ ច្បាប់ |
| ២-ច្បាប់ចម្លងសញ្ញាប័ត្រដែលមានការបញ្ជាក់ទទួលស្គាល់ជាផ្លូវការ | ចំនួន ០១ ច្បាប់ |
| ៣-ជីវប្រវត្តិសង្ខេបមានបិទរូបថត ៤ X ៦ | ចំនួន ០១ ច្បាប់ |
| ៤-សលាកប័ត្រឯកត្តជន | ចំនួន ០២ ច្បាប់ |
| ៥-រូបថតថ្មី ៤ X៦ (ថតចំពីមុខ) | ចំនួន ០២ សន្លឹក |
| ៦-បង្កាន់ដៃទទួលពាក្យ | ចំនួន ០២ ច្បាប់ |
| ៧-កិច្ចសន្យា | ចំនួន ០១ ច្បាប់ |
| ៨-ច្បាប់ចម្លងប័ណ្ណគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ | ចំនួន ០១ ច្បាប់ |
| ៩-លិខិតថ្កោលទោស (ក្រោយពេលប្រឡងជាប់) | ចំនួន ០១ ច្បាប់ |

**ឃ-វិញ្ញាសាប្រឡង :**

១-វិញ្ញាសាវប្បធម៌ទូទៅ *មេគុណ ១ រយៈពេល ២ម៉ោង*

២-វិញ្ញាសាភាសាអង់គ្លេស *មេគុណ ១ រយៈពេល ១ម៉ោង៣០នាទី*

៣-វិញ្ញាសាសេដ្ឋកិច្ចពាណិជ្ជកម្ម ឬវិញ្ញាសាដែលទាក់ទងនឹងមុខជំនាញដែលបេក្ខជនស្នើសុំចុះឈ្មោះប្រឡងដូចបានកំណត់បញ្ជាក់ខាងលើ *មេគុណ ២ រយៈពេល ២ម៉ោង*

**ង-កាលបរិច្ឆេទ និង មណ្ឌលប្រឡង :**

- កាលបរិច្ឆេទប្រឡង: **ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១១**

*<u>ពេលព្រឹក</u> ចាប់ពីម៉ោង ៧,៣០ រហូតដល់ម៉ោង ១១,៣០នាទី វិញ្ញាសាវប្បធម៌ទូទៅ និងភាសាអង់គ្លេស*

*<u>ពេលរសៀល</u> ចាប់ពីម៉ោង ១៤,៣០ រហូតដល់ម៉ោង ១៦,៣០នាទី វិញ្ញាសាសេដ្ឋកិច្ចពាណិជ្ជកម្ម និងវិញ្ញាសាតាមវិស័យជំនាញការងារ*

- មណ្ឌលប្រឡង៖ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ក្នុងករណីចាំបាច់ពាក់ព័ន្ធទៅនឹងចំនួនបេក្ខជន ដែលនាំឲ្យមានការផ្លាស់ប្តូរមណ្ឌលប្រឡង គណៈកម្មការនឹងធ្វើការជូនដំណឹងនៅមុនថ្ងៃប្រឡងចំនួន ៥ថ្ងៃ។

ព័ត៌មានលម្អិតផ្សេងៗទៀត បេក្ខជនអាចមកទំនាក់ទំនងដោយផ្ទាល់នៅលេខាធិការដ្ឋាននៃគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការរបស់ក្រសួងពាណិជ្ជកម្ម នៅទីស្តីការក្រសួងពាណិជ្ជកម្ម (នាយកដ្ឋានបុគ្គលិក) រាល់ម៉ោងធ្វើការ។

*កំណត់សម្គាល់* ៖

- ចំពោះកាលបរិច្ឆេទនៃការឈប់ទទួលពាក្យសុំចុះឈ្មោះប្រឡង និងកាលបរិច្ឆេទនៃការប្រឡងដែលក្រសួងពាណិជ្ជកម្មបានចេញសេចក្តីជូនដំណឹងលើកដំបូង លេខ ៣២៨៣ ពណ.បល.សជណ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០១១ ត្រូវពន្យាពេល និងអនុវត្តតាមកាលបរិច្ឆេទនៃសេចក្តីជូនដំណឹងនេះវិញ។

**ប្រធានគណៈកម្មការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ**
**ចូលបម្រើការងារក្នុងក្របខ័ណ្ឌក្រសួងពាណិជ្ជកម្ម ឆ្នាំ២០១១**
**និងជាអនុរដ្ឋលេខាធិការ**

**ម៉េង សុធី**

**ចម្លងជូន ៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
*"ដើម្បីជូនជ្រាប"*
-គ្រប់អគ្គនាយកដ្ឋាន អង្គភាព មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត
-ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន
*"ដើម្បីជួយផ្សព្វផ្សាយ"*
-ឯកសារ-កាលប្បវត្តិ